00008502

L00014445 (05 00F) D64

1. 89
2. 31
3. ស៊ុ
4. ផាកា

**Declassified to Public**
**06 September 2012**

កំណត់ហេតុ នៃការប្រជុំ ខាង
មន្ទីរអង្គការ ៧០៣ និង ស.២១

ថ្ងៃ ៨-៨-៧៦

<u>បញ្ហារើសបានខិត្តប័ណ្ណ</u> -

- ថ្ងៃពុធ ៧-៨-៧៦ ម៉ោង ១០,៣០ លើផ្លូវជិតវត្តបុទុម ខាងកើតវត្តបុទុម ។ ខិតប័ណ្ណ ១២ សន្លឹក ។

- បងប្អូនរើសបាន ពេលបួរយាម ។ បានពិនិត្យសភាពការណ៍ឆ្ងាយ ដែរកពុំឃើញសណ្ឋានអ្វីទៀត ។ ពេលនោះ ផ្លូវនៅនោះងងឹតបន្តិច ។ អ្នកយាមម្នាក់ឲ្យការណ៍ថា ម៉ោងហ្នឹង មានមនុស្សម្នាក់ដើរពីវិមានឯករាជមក ។ សួរថា មិនស្គាល់ មិនមែនគ្នាឯង ។

- <u>ស្ថានភាពបរិស្ថាន</u> : លទ្ធភាពមនុស្សនេះចូលធ្វើសកម្មភាពតាមប្រឡាយផ្លូវនរោត្តម ហើយចេញវិញ តាមផ្លូវខ្សែរដើមពោធិមុខវត្ត ងាកទៅត្បូង ខ្សែរទៅងាយមួយ ។ មនុស្សនេះ តាមមើលទៅ ពីក្រៅហើយ មានលមត្ថភាពខ្ពស់ បើមើលលទ្ធភាពពួកពីក្នុង ក៏ពិបាកដែរ ។

- ខ្លឹមសារខិត្តប័ណ្ណ ដូចគ្នានឹងខ្លឹមសារដែលវាបោះមុន ខ្សែរទូតចិន ។ មនុស្សជំនឿវាធ្វើ ។ នុទាហរណ៍ ពាក្យ ស៊ីតូចដោយតូច ស៊ីធំដោយធំ និងពាក្យ អង្គការបដិវត្តថ្មីបរិសុទ្ធ ។

- យប់ថ្ងៃ ៧ ម៉ោង ៨ ទៅ ៩ ដដែល មានមនុស្សម្នាក់ខ្មែរអាត់ មានខ្លឹមសារ កងទ័ពត្រូវអនុវត្តផ្ដាច់ការរបស់បក្ស ។ ព្រួតធ្ងន់ផ្ទះសមមិត្ត សន លេខាវរៈសេនាធំ ៣១ នៅកងពល ៧០៣ ។ មិនពួដែរ គេឃើសណ្ដាប់ដែរ ។

- <u>សមមិត្ត ពីន</u> -

អង្គភាពនេះ ក្រោយមានព្រឹត្តិភាពលើកមុន បានចូលអង្គភាពថ្មីមកជំនួសមុខសញ្ញា ។ កន្លងមក កងនេះមានបញ្ហា មកដំបូង យកអង្គរអង្គការ ។ កន្លងមក សមមិត្ត សន មានអប់រំនយោបាយឲ្យបងប្អូន រវាង ២-៣ ថ្ងៃក្រោយ ។

- <u>សមមិត្ត ឡុប</u> -

ខ្មែរខិត្តប័ណ្ណពីមុន យើងចាប់អាសមន្ត្រ ។ សួរអាណាត - អាយ៉ាត់ថា ខិតប័ណ្ណយកពី ភ្នំកងពល ១៧០ ។ តាមសន្និដ្ឋាន វាអាចបោះក្រចីន នៅមុខសញ្ញាដទៃដែរ តែបងប្អូនមិនដែលចាប់អារម្មណ៍លើបញ្ហានេះ ។

- <u>បង ផស</u> -

១- ខិតប័ណ្ណនេះ ខ្លឹមសារតែមួយ ក្បាលម៉ាស៊ីនតែមួយ ។ យើងឯកភាពគ្នាលើចំណុចនេះ ។

00008503
D64



២- ជិតមកបោះ ទេព្រោះភ្ជាប់សភាពការណ៍បាន ?

៣- ឆ្ងាយមកបោះបានដែរ ?

ត្រូវពិនិត្យកង ១៨០ , កង ៧០៣ , និងអង្គភាពផ្សេងទៀត ដែលបោះទីក្បែរនោះ ។

មតិសរុបបង ៨៩ -

១- ពិនិត្យខ្លឹមសារខិតប័ណ្ណ ដូចអាខែ ៦ និងខែ ៧ ។ ខិតប័ណ្ណនេះ ធ្វើនៅជិត នៅភ្នំពេញ ។ ធ្វើនៅកន្លែងធ្វើការប្រលបច្បាប់ ជាមន្ទីរកងពល- វរៈសេនាធំ ឬក្រសួងផ្សេង ៗ ។

២- បញ្ហានេះ មិនមកពីក្រៅទេ ។

៣- គោលគំនិត អាចពីក្រៅ ឬនៅជិត ក្រៅពីកងទ័ព ។

៤- ខ្សែវាជាប់កងពល ១៧០ ច្រើន - ក្នុងអង្គភាពបច្ចុប្បន្ន ឬ ១៧០ ឱ្យទៅឧស្សាហកម្ម ។ ឬពួក ២២០ ដែលកាលពីដែលបញ្ចូលមក ។ ពួក ៧០៣ ដែលមកពីតំបន់ ២៥ ឬពួកនៅកសិដ្ឋានរដ្ឋ ខ្សែវាពីតំបន់ ២៥ ។

៥- វាបោះបាន ត្រូវតែភ្ជាប់សភាពការណ៍ប្រចាំថ្ងៃ ប្រចាំម៉ោងបាន ។ ដូច្នេះ វានៅជិត ឬនៅក្នុងកងការពារយើង ជាអ្នកឱ្យពត៌មាន ។ ខ្មាំងចង់ឱ្យយើងឈប់ទុកចិត្តកង ៧០៣ និង ១៨០ ។

៦- បញ្ហាខិតប័ណ្ណនេះ មិនមានខាតអីដល់យើង គ្រាន់តែជាការរុករក បំផុសប្រមូលកំលាំងវា និងបំបែកកំលាំងយើង ។ សកម្មភាពនេះ ជាផែនការរួមរបស់ខ្មាំង ។ ត្រូវប្រយ័ត្នខ្មាំងលួចបាញ់អង្គការ ។ ប្រយ័ត្នទុកក្នុង ដែលនៅជិតយើង ។

វិធានការ :

១- ចលនានេះប្រុងប្រយ័ត្នបដិវត្តន៍ឱ្យខ្ពស់ ដោយទំនាស់កាន់តែស្រួចណាស់ កំហឹងវណ្ណៈរបស់ខ្មាំង ទាំងខាងលិច ទាំងខាងកើត ចំពោះបដិវត្តន៍កម្ពុជា កាន់តែខ្លាំងណាស់ ។ ត្រូវតែវាយយើង វាទុកយូរទៀត មិនបានទេ ។

២- បញ្ហាចាត់តាំង សមមិត្ត ប៉ាំ និង ខាមី ត្រូវឃើញភារកិច្ចផ្លូវ , ខំអប់រំនយោបាយ សតិអារម្មណ៍ឱ្យជាប់ , ភ្ជាប់ប្រវត្តិរូប ភ្ជាប់សតិអារម្មណ៍ឱ្យជាប់ ។ ប្រយ័ត្នកុំឱ្យមានទំនាស់សតិអារម្មណ៍ ខ្មាំងអូសបាន ទិញបាន ។ អ្នកណាយើងសង្ស័យ ត្រូវយកចេញ ។ ត្រូវខំរកដែរ ពិនិត្យមេតុ ភេទកន្លែងនោះ ។

- ខាងក្រៅ សមមិត្ត ពីនពិនិត្យអង្គភាពឡើងវិញ ដើម្បីហ្នឹង យ៉ាងហ្នឹង សកម្មភាព យ៉ាងម៉េច ? ចិលរក គឺខ្សែអាយុខចាស់ ។ ខ្លឹមសាររៀនសូត្រ ស្នើរដើរអប់រំយ៉ាងម៉េច ? យើងចង់ត្រង់និយាយប្រៀបធៀបបដិវត្តន៍យើង ជាមួយបរទេស ។

- សន្តិសុខ ស្មើតាមជានសភាពការណ៍ខ្មាំងថែម ។

- ស្នើសមមិត្ត ប៉ាំ ទាក់ទងក្រសួងផ្សេង ៗ ។ ពួក ១៧០ នូវប្រមូល ។